# ការសំភាសន៍របស់អ៊ុំស្រី ប្រុក វ៉ន

កៈ អ្នកដែរសំភាសន៍គេមានឈ្មោះ ជាងស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ ប្រុក វ៉ន

<u>ការសង្ខេបប្រវត្តិរបស់អ៊ុំស្រី ប្រុក វ៉ន</u>

អ៊ុំស្រី ប្រុក វ៉ន មាន អ៊ុំស្រី ប្រុក វ៉ន មានភេទស្រីអ៊ុំស្រី ប្រុក វ៉ន
មានទីលំនៅបច្ចុប្បន្ននៅភូមិ។

កៈ
ចឹងជាដំបូងខ្ញុំសូមអរគុណាច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សារីការសំភាសន៍ពីប្រវត្តិរបស់អ៊ុំ
ហើយការពិភាក្សារីការសំភាសន៍
នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU
ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បី
ទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយ
នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន
ពិភាក្សារីក៏សំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សា
លាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ
ចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍
មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ អានឹងសំភាសន៍យកធ្វើអីគេដែរក្មួយ?

កៈ ដាក់ដើម្បីតំកល់ដើម្បីដាក់ទុកអោយកូនចៅរបស់អ៊ុំបានស្គាល់ពីប្រវត្តិរបស់អ៊ុំ?

ខៈ ចុះដាក់ទៅមានអីក្មួយ

កៈ បាទចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ
ហើយការសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី23 ខែ2 ឆ្នាំ2018
ហើយការសំភាសន៍មួយនេះត្រូវបានធ្វើនៅភូមិដក់ពរ ឃុំវល្លិ៍សរ ស្រុកសំរោងទង
ខេត្តកំពង់ស្ពឺ?

ខៈ ចាំ!!!!នឹងហើយ

ក៖ ចឹងសំរាប់អ៊ុំមានឈ្មោះពេញនឹងឈ្មោះអីគេដែរអ៊ុំ?

ខ៖ ខ្ញុំឈ្មោះអ៊ឹម ថន

ក៖ ចុះមានឈ្មោះហៅក្រៅដែរទេអ៊ុំ?

ខ៖ មានដែរតើនឹង

ក៖ ឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖ ឈ្មោះពៅ

ក៖ ឈ្មោះពៅ ចុះកាលពីក្មេងនឹងមាននរណាហៅឈ្មោះអ៊ុំអីផ្សេងទៀតទេអ៊ុំ?

ខ៖ អត់មានទេនឹងគេហៅតែចឹងហាសអូន

ក៖ ចុះសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំអាយុ57ឆ្នាំ

ក៖ ចុះអ៊ុំមានចងចាំថាអ៊ុំកើតនៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខ៖ ដូចជាភ្លេចហើយក្មួយខ្ញុំកើតនៅឆ្នាំ2062

ក៖ នៅឆ្នាំ1962ហីអ៊ុំ?

ខ៖ ចា៎!នៅឆ្នាំ1962នឹង

ក៖ ចុះសំរាប់ឆ្នាំច័ន្ទគតិនឹងអ៊ុំមានដឹងថាអ៊ុំឆ្នាំអីគេដែរទេអ៊ុំ?

ខ៖ ខ្ញុំឆ្នាំខាលនឹង

ក៖ អ៊ុំឆ្នាំខាលណអ៊ុំ ចុះអ៊ុំកើតនៅណាដែរអ៊ុំ?

ខ៖ ខ្ញុំកើតនៅព្រៃវាំងហោសនេះមិនមែនភូមិខ្ញុំទេនេះហោសនៅភូមិខ្ញុំខាងលិចហោស

ក៖ នៅភូមិអី ឃុំអី ស្រុកអីអ៊ុំ?

ខ៖ តែយើងនៅនេះចឹងយើងដាក់នៅនេះទៅនឹងនៅនេះនឹងទៅ

ក៖ បាទនៅភូមិដក់ពរនឹងហោសអ៊ុំ?

ខ៖ ចាំៗៗ!!!នឹងហើយ

ក៖ ចុះសំរាប់អ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ កាលពីជំនាន់អាពតនឹងមានបងប្អូន9នាក់ប៉ុន្តែឥឡូវនឹងនៅសល់តែ4នាក់ទេក្មួយ

ក៖ អូ!ចឹងមានន័យថាស្លាប់អស់5នាក់ហោស
ប៉ុន្តែអ៊ុំមានចងចាំឈ្មោះពួកគាត់ទាំងអស់ទេអ៊ុំ?

ខ៖ អ្នកស្លាប់ហោស?

ក៖ ទាំងអ្នកស្លាប់នឹងអ្នកនៅរស់ហាស?

ខ៖ មានចងចាំតើអូន

ក៖ ប៉ុន្តែមានស្រីប៉ុន្មាននាក់ ហើយនឹងមានប្រុសប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ ប្រុសមានតែ2ទេ សំរាប់ស្រីនឹងមាន6នាក់

ក៖ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំកូន៣គេនឹង

ក៖ អូ!ចឹងបងៗៗរបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរឈ្មោះទាំងអស់ហាសអ៊ុំ?

ខ៖ ឈ្មោះទីមួយនឹងប៉ុន្តែបងស្លាប់ហើយណាស់អូនឈ្មោះ គុណ

ក៖ ឈ្មោះយាយគុណ?

ខ៖ ឈ្មោះអឹម គុណនឹង ដល់ឈ្មោះទីពីរនឹងឈ្មោះអឹម គយ ឈ្មោះអឹម ថាច ហើយឈ្មោះ
អឹម ថោង ហើយនឹងខ្ញុំអឹម ថន

ក៖ អូ!នឹងអ្នកដែរនៅរស់នឹង?

ខ៖ ចាំៗ!អ្នកដែរនៅរស់នឹងមានតែយាយអឹម គយ ហើយឈ្មោះអឹម ថាច
នឹងឈ្មោះអឹមថោង មានតែ4នាក់នឹងទេ

ក៖ បាទហើយនឹងអ៊ុំ?

ខ៖ ចាំ!នឹងហើយ

កៈ ចុះអ៊ុំធ្លាប់ចងចាំអនុស្សាវរីយ៍អីគេកាលពីនៅក្មេងៗជាមួយពួកគាត់ហាស ដូចជាលេងឡឹកបាយឡ លេងបិទពួន

ខៈ កាលបីជំនាន់ណុងមិនបានលេងអីទេក្មួយអើយកាលនៅតូចនឹងយើងអាពតនឹងរហូតចឹងទៅ ហើយបានលេងអីអាពតមិនអោយលេងទេ អាពតនឹងយើងអត់ចាយលុយ

កៈ ប៉ុន្តែធ្លាប់ទៅវាលស្រែអីជាមួយគ្នាតើហីអ៊ុំ?

ខៈ អត់ទេកាលណុងខ្ញុំប្រហែលជាកំពស់នេះ

កៈ អូ្!ចឹងទេហោស?

ខៈ ហើយខ្ញុំអត់ដែរពាក់អាវ ពាក់តែខោមួយនឹងទេ

កៈ អូ្!ពេលលណុងអ៊ុំនៅណាដែរទៅអ៊ុំ?

ខៈ ខ្ញុំនៅភូមិត្រពាំងណោះបានខ្ញុំរត់ហោស

កៈ អូ្!ប៉ុន្តែបងៗរបស់អ៊ុំនឹងគាត់ទៅណាទៅ?

ខៈ បងៗរបស់ខ្ញុំនឹងនៅរត់ជុំគ្នានឹង ប៉ុន្តែគ្រាន់តែពីរបាត់នៅជំនាន់អាពតទាំងអស់

កៈ ប៉ុន្តែនៅបែកគ្នាមែនទេអ៊ុំ?

ខៈ នៅបែកគ្នាបងៗនឹង ហើយមានប្រុសតែ2នាក់នឹងទេ ឈ្មោះបងផាន់ នឹងបងចុល

កៈ ប៉ុន្តែឥឡូវនឹងគាត់បាត់ខ្លួនទាំងពីរនឹង?

ខៈ ចា៎!បាត់អស់ហើយ

កៈ ចុះអ៊ុំគិតថាគេជំលាសអ៊ុំទៅណាវិញទៅនឹង?

ខៈ ខ្ញុំនៅភូមិត្រពាំងនឹងដែរ

កៈ ចុះឪពុកម្តាយរបស់អ៊ុំវិញ?

ខៈ គាត់ក៏នៅនឹងដែរប៉ុន្តែគាត់ស្លាប់អស់ហើយអូនអើយ

កៈ អូ្!គាត់ស្លាប់កាលពីជំនាន់ពលពតមែនទេអ៊ុំ?

ខ៖ ឪពុកស្លាប់ពេលដែរពលពត ឯម្ដាយស្លាប់នៅពេលនេះទេ

ក៖ ចុះអ៊ុំគិតថាបងៗរបស់អ៊ុំនឹងគាត់ស្លាប់នៅជំនាន់ពលពតរឺក៏មិនមែនទេអ៊ុំ?

ខ៖ ស្លាប់បងស្រីពីរនឹង

ក៖ ប៉ុន្តែបងប្រុសពីរនាក់ទៀតបាត់ខ្លួនមិនដឹងទេ?

ខ៖ ពីរនាក់នឹងបានបាត់ជំនាន់អាពតនឹង

ក៖ ទាល់តែឥឡូវនឹងក៏មិនដឹងថាទៅណាគេដែរចឹង?

ខ៖ មិនដឹងទេនឹង

ក៖ ចុះកាលពីអ៊ុំនៅជំនាន់ពលពតនឹងអ៊ុំជាកងកុមារ?

ខ៖ ចាំ!!ជាកងកុមារ

ក៖ ចុះគេអោយអ៊ុំធ្វើអីគេខ្លះដែរទៅ?

ខ៖ ខ្ញុំចិញ្ចឹមជ្រូក

ក៖ គេអោយអ៊ុំចិញ្ចឹមជ្រូក?

ខ៖ នេះចិញ្ចឹមជ្រូកពីរនាក់ផ្ទះខាងលិចនេះនឹងតែឥឡូវនឹងវាឈឺដូចខ្ញុំចឹង

ក៖ អ៎ូ!ទៅអោយបាយជ្រូក ទៅហាន់គល់ចេកអីចឹងហើយណាអ៊ុំ?

ខ៖ អត់ទេជំនាន់អាពតនឹងជួបជុំគ្នាទៅដកផ្ទី

ក៖ គេអោយតៅដកផ្ទី?

ខ៖ ទៅដកផ្ទីដើម្បីចិញ្ច្រាំបបរនឹង

ក៖ ប៉ុន្តែគេមានអោយយើងកើបអាចម៍ជ្រូករឺមួយក៏បាញ់អាចម៍ជ្រូកអីទេ?

ខ៖ អត់មានទេគ្រាន់តែអោយបាយបន្តិចនឹងគ្មានធ្វើអីទេនឹង

ក៖ ខាងគេនោះផ្សេងទៀតទៅនឹង?

ខ៖ ចា៎!ជ្រូកមាន20ក្បាលជាងនឹងហើយចិញ្ចឹមតែ3នាក់នឹង

កៈ ស្លាប់ហើយច្រើនណាស់អ៊ុំ?

ខៈ មានច្រើនណាស់អូន

កៈ ចុះរួចទៅរបបអាហារនឹងយ៉ាងម៉េចទៅចឹង?

ខៈ យើងទៅបោចផ្ទីនឹងដើម្បីទៅចិញ្រ្ចាំបបរបាយជ្រូកនឹង

កៈ ប៉ុន្តែរបបអាហារមនុស្សយើងវិញហាស កាលពេលណុងហាស?

ខៈ មានចុងភៅគេធ្វើតើអូន គេមានចុងភៅគេដាំបបរនឹងយើងមិនបានហូបបាយទេ យូរៗគេអោយ ហូបបាយបានម្តងចឹងទៅណាស់អូនកាលពីជំនាន់អាពតហាស

កៈ បាទអ៊ុំ
ប៉ុន្តែអ៊ុំខ្ញុំសុំសួរបន្តិចបានទេត្រង់ថាអោយបាយជ្រូកនឹងយើងអោយបាយជ្រូកត្រង់ថាយើង អោយបាយជ្រូកតែមួយពេលៗបន្តិចៗនឹងដូចជាយើងមិនត្រូវមានបញ្ហាអីត្រូវយើងហាត់ ទេណាអ៊ុំ?

ខៈ អត់អីទេគ្រាន់តែពីដើមនឹងយើងហូបតែបបរនឹង
វាហេវហាសអូនជំនាន់អាពតនឹងអត់អោយហូបបាយទេបួនទៅប្រាំខែនឹងគេអោយហូបបា យបានម្តងនឹង

កៈ ចុះកាលអ៊ុំនៅជំនាន់កងកុមារនឹងនៅគ្នាច្រើនមែនទេអ៊ុំ?

ខៈ នៅច្រើនណាស់នៅរាប់ពាន់កុមារណោះនៅគេហៅត្រពាំងណ៉ន

កៈ បាទចុះអ្នកមកអោយបាយជ្រូកនឹងមានច្រើនដែរ?

ខៈ មានតែ5-6នាក់នឹងក្មេងៗគ្នាខ្ញុំនឹង

កៈ
ចុះគេគិតយ៉ាងម៉េចទៅអ៊ុំគេគិតថាមួយយើងធ្វើបែបណាបានអោយយើងសំរាកបានចឹងហា ស?

ខៈ អោយតែពេលយប់ចឹងយើង
អោយតែពេលថ្ងៃរឺមួយក៏ពេលល្ងាចនឹងអោយជ្រូកនឹងស៊ីបាយហើយ

ដល់ពេលយប់ឡើងយើងដេកទៅទៅដេកនៅកន្លែងយើងផ្សេងទៅដល់ពេលព្រឹកឡើងយើងរកអីបបរទៀតទៅណាអូនចឹង

ក៖ ប៉ុន្តែព្រឹកព្រលឹមឡើងថ្ងៃអីយើងទៅរកផ្ទីអីសំរាប់មកអោយជ្រូកនឹង?

ខ៖ ចាំ!នឹងហើយ

ក៖ ចុះអ៊ុំគិតថាបងៗៗរបស់អ៊ុំពេលណុងទៅណាទៅ?

ខ៖ បងៗៗរបស់ខ្ញុំកាលពីជំនាន់ពលពតហោស?

ក៖ បាទអ៊ុំបាទ?

ខ៖ បែកគ្នាទាំងអស់នឹងណាស់

ក៖ ប៉ុន្តែពួកគាត់នឹង?

ខ៖ គេនៅភូមិផ្សេងៗៗពីគ្នានឹង

ក៖ មានដឹងថាពួកគាត់ទៅណាហើយពួកគាត់ធ្វើអីទេអ៊ុំ?

ខ៖ ប៉ុន្តែពេលឥឡូវនឹងនេះនៅជុំគ្នា2នាក់ទៅបុណ្យបាត់ហើយនឹងនៅតែ2នាក់ទេនឹង

ក៖ អូ៎!ប៉ុន្តែចង់និយាយថាពេលពលពតហាស គេអោយពួកគាត់ធ្វើអីគេខ្លះដែរទៅអ៊ុំ?

ខ៖ ធ្វើអីជំនាន់អាពតនឹងធ្វើស្រែធ្វើអីចឹងទៅណាស់អូន

ក៖ ប៉ុន្តែម្តាយរបស់អ៊ុំនឹងធ្វើអីគេដែរ?

ខ៖ ម៉ែរបស់ខ្ញុំនឹងគាត់នៅផ្ទះ

ក៖ គេអោយនៅផ្ទះហោសអ៊ុំ?

ខ៖ នៅផ្ទះមើលចៅនឹង

ក៖ ប៉ុន្តែកាលពីមុននឹងគេអោយនៅផ្ទះមើលចៅ?

ខ៖ ចាំ!នៅមើលចៅ

ក៖ អូ៎!ម៉េចចឹងអ៊ុំគេអោយធ្វើអីផងហោសអ៊ុំ?

ខ៖ ម៉េចចឹងម៉េចចាស់ៗៗនឹងគេអោយនៅមើលក្មេងនឹង

ក៖ អូ៎!នៅមើលក្មេងហោស?

ខ៖ ចុះម៉ែឪទៅស្រែនឹងដុចចៅឯង

ក៖ អូ៎!ដោយសារតែខ្ញុំអត់ដឹងចឹងហាសអ៊ុំ ខ្ញុំចេះតែឆ្ងល់ចឹងហាស?

ខ៖ ចៅឯងមិនទាន់ជំនាន់អាពតចឹងហើយ

ក៖ បាទដល់ពេលចឹងតែងតែមានសំនួរច្រើនចង់សួរអីចឹងហាសអ៊ុំ?

ខ៖ ចាំ!ត្រឹមត្រូវហើយចៅ

ក៖ ចឹងនៅក្នុងរយះពេល3ឆ្នាំ8ខែនឹងគឺអ៊ុំធ្វើតែអានឹងរហូតតែម្តង?

ខ៖ នឹងហើយខ្ញុំនៅចិញ្ចឹមជ្រូកនឹង

ក៖
អូ៎!ចុះពេលដែរគេរំដោះហើយនឹងពេលណុងគ្រួសាររបស់យើងនឹងមកនៅជុំគ្នាវិញហើយណាអ៊ុំ?

ខ៖ មកចឹងទៅបានមកនៅជុំគ្នា

ក៖ ចុះមកនៅជុំគ្នាចឹងមានការលំបាកអីផ្សេងទៀតអត់អ៊ុំ?

ខ៖ អត់ពិបាកអីទេក្មួយបងប្អូនរបស់ខ្ញុំនឹងអត់ចេះលំបាកអីទេនឹង

ក៖
ប៉ុន្តែបើខ្ញុំលឺគេនិយាយថានៅពេលដែរយើងដាច់ពលពតហើយយើងនៅមានការលំបាកម្តងទៀត ត្រង់លំបាកថាយើងអត់មានអីយើងត្រូវទៅធ្វើស្រែចំការ
ដើម្បីអាចដោះយកបាយអីមកញាំុមែនទេអ៊ុំ?

ខ៖ ចឹងមុនដំបូងចឹងហើយក្មួយអើយធ្វើរួមធ្វើស្រែនឹង

ក៖ ធ្វើប៉ុន្តែពេលណុងអត់ចាយលុយទេមែនទេអ៊ុំ?

ខ៖ អត់ទេនឹង

កៈ គេដូរគ្នា?

ខៈ
គេធ្វើស្រែរូមនឹងគេបានចឹងទៅគេថ្លឹកគីឡូចែកគ្នាហើយនឹងជំនាន់យើងទើបតែមកហាសក្មួ
យ

កៈ ហើយដល់ពេលណុងយើងដោះយកអង្ករចឹងទៅហើយចែកគ្នាញ៉ាំចឹងទៅ

ខៈ នឹងហើយចឹង

កៈ រួមទៅពេលដែរទិញម្ហូបអីនឹងគេដូរអង្ករដើម្បីទិញទៅ?

ខៈ ចា៎!គេធ្វើចឹង

កៈ ចុះរបៀបគេការនឹងគេការរបៀបណាដែរទៅអ៊ុំ កាលពីជំនាន់ណុង?

ខៈ គេការនឹងគេមានចំណងដៃ
គេមានចុងភៅគេហាសក្មួយយើងហៅគេមកណាស់ក្មួយឧបម៉ាថា
ចំណងដៃនឹងតុមានតែ70-80តុទេ ឥឡូងនឹងទាល់តែ110-120ហោស

កៈ
កាលពីជំនាន់ណុងគេមិនទាន់ចាយលុយដល់ពេលដែរគេជួលចុងភៅមកគេធ្វើម៉េចទៅអ៊ុំ?

ខៈ អូ៎!ការជំនាន់អាពតហោស?

កៈ កាលពីជំនាន់អាពត
នឹងពេលដែរជំនាន់ដាច់ពលពតថ្មីៗនឹងគេមិនទាន់ចាយលុយមែនទេអ៊ុំ?

ខៈ ពេលណុងនៅទេ

កៈ ចុះពេលដែរយើងការនឹងយើងធ្វើយ៉ាងម៉េចដែរទៅ?

ខៈ យើងការនឹងយើងការតិចតួចនឹងយើងមានត្រី
មានសាច់ចឹងយើងស្លទៅហើយហៅបងប្អូនមកហូប
ចឹងទៅគិតថាយើងមិនចងដៃមែនប៉ុន្តែយើងហូបហើយនឹងយើងជូនពរអ្នកការចឹងទៅហើ
យបាត់ហើយ នឹងណាស់គ្មានអីទេក្មួយ

កៈ អូ៎!ប៉ុណ្ណឹងហោសអ៊ុំ?

ខៈ ចា៎!មានតែប៉ុណ្ណឹង

កៈ ចង់និយាយថានឹងម្តងគេម្តងយើងទេណាអ៊ុំ?
ខៈ នឹងហើយចឹង

កៈ ចុះកាលពីនៅក្មេងៗនឹងអ៊ុំចូលចិត្តលេងអីគេជាមួយបងប្អូនរបស់អ៊ុំដែរទៅ?

ខៈ មិនដឹងថាលេងអីទេក្មួយអើយអត់មានអីលេងទេនៅជំនាន់ពលពតនោះ

កៈ អ៊ុំកើតមកនឹងដល់ជំនាន់ពលពតតែម្តង?

ខៈ ចា៎!វាធ្វើអោយយើងនឹងពិបាកវេទនាណាស់

កៈ បាទអ៊ុំចឹង?

ខៈ ប៉ុន្តែបងប្អូននឹងនេះបងថ្លៃខ្ញុំហើយនឹង

កៈ អូ៎!ចឹងហោសអ៊ុំ?

ខៈ នៅមើលក្មួយនឹងក្មួយរបស់ខ្ញុំបង្កើតតើនឹង

កៈ ចុះអ៊ុំគិតថាបងប្អូនរបស់អ៊ុំនឹងសព្វថ្ងៃនឹងគាត់នៅណាខ្លះដែរទៅ?

ខៈ នៅតែមួយភូមិនឹងទេ

កៈ នៅក្នុងភូមិនឹងទាំងអស់គ្នាទេនឹង?

ខៈ នៅភូមិនឹងតែ4នាក់ទេតែ2នាក់បានទៅបុណ្យបាត់ហើយនឹង នៅតែ2នាក់ទេនឹង

កៈ ប៉ុន្តែនៅក្នុងភូមិដក់ពរនឹងទាំងអស់គ្នានឹង?

ខៈ ចា៎!នៅនឹង

កៈ ចុះពួកគាត់ធ្វើអីគេដែរអ៊ុំដើម្បីរកស៊ីចិញ្ចឹមជីវិតហាស?

ខៈ គេធ្វើតែស្រែទេនឹងហើយកូនៗនឹងធ្វើការងាររោងចក្រ

កៈ អូ៎!បាទចុះឪពុករបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖  ឪពុករបស់ខ្ញុំនឹងជីតាខ្ញុំឈ្មោះឈឿន ឪពុករបស់ខ្ញុំ

ក៖  ចុះម្ដាយរបស់អ៊ុំវិញ?

ខ៖  គាត់ឈ្មោះសឿន

ក៖  ចុះគាត់កើតនៅឆ្នាំណាដែរអ៊ុំចងចាំទេ?

ខ៖  អត់ដឹងទេខ្ញុំដឹងថាម្ដាយយាយសឿននឹងកើតឆ្នាំចរ

ក៖  គាត់កើតនៅឆ្នាំចរណាអ៊ុំ?

ខ៖  គាត់ឆ្នាំចរពីដើមនឹងចូល90ឆ្នាំជាងអីនឹង

ក៖  ចុះគាត់កើតនៅណាដែរអ៊ុំ?

ខ៖  គាត់កើតនៅនឹង

ក៖  គាត់កើតនៅនឹងតែម្ដងហោសតា?

ខ៖  នឹងហើយនៅនឹង

ក៖  អូ៎!ចុះឪពុកម្ដាយនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរ?

ខ៖  អត់ដឹងទេក្មួយអើយគាត់ធ្វើតែស្រែទេនឹង

ក៖  ចឹងខ្ញុំអាចនិយាយជាមួយតា អ៊ុំមិនសូវដឹងច្រើនទេណាអ៊ុំ ដោយសារតែអ៊ុំបានភ្លេចច្រើន?

ខ៖  ខ្ញុំបានភ្លេចច្រើនណាស់ក្មួយ

ក៖  ប៉ុន្តែតាគាត់ចាំច្រើនដែរតើហីតា?

ខ៖  ចុះគាត់បងរបស់ខ្ញុំគាត់ចាំច្រើន

ក៖  ចុះខ្ញុំអាចសុំសួរជាមួយគ្នាតែម្ដងនឹងបានទេតា?

ខ៖  ថាម៉េចសួរអីគេ តាឯងដឹងអីឆ្លើយនឹងទៅ

កៈ
គ្រាន់តែខ្ញុំសួរតាអីចឹងទៅតាដឹងតាអាចឆ្លើយចឹងទៅណាស់តាដោយសារតែតាត្រូវជាបង
គាត់?

ខៈ បាទមិនអីទេ

កៈ ប៉ុន្តែតាគិតថាឪពុករបស់តានឹងស្លូតរឺមួយក៏កាចដែរតា?

ខៈ គាត់ស្លូតណាស់

កៈ គាត់ស្លូតណាតា?

ខៈ បាទគាត់ស្លូតនឹង

កៈ ចុះម្តាយរបស់តាគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរតា?

ខៈ ធ្វើស្រែចំការជាមួយយាយសឿននឹងហោស?

កៈ អត់ទេម្តាយរបស់តានឹងហាស?

ខៈ ម្តាយយាយសឿននឹងហោស ម្តាយអ៊ុំឯងនឹងហាស?

កៈ បាទតាគាត់ធ្វើអី?

ខៈ គាត់ធ្វើអីគ្រាន់តែធ្វើស្រែនឹង

កៈ គាត់ធ្វើតែស្រែទេហោសតា?

ខៈ នឹងហើយ

កៈ អ៊ូ!ចុះគាត់ជាមនុស្សបែបណាដែរគាត់ស្លូតរឺមួយក៏កាចដែរតា?

ខៈ គាត់ស្លូតណាស់នឹង

កៈ តាអង្គុយទៅតា

ខៈ ម៉ែរបស់ខ្ញុំនឹងបងប្អូនរបស់ខ្ញុំពីមុននឹងគ្មាននរណាគេពិបាកទេ

កៈ ចុះកាលពីតានៅជាមួយពួកគាត់នឹងធ្លាប់មានអនុស្សាវរីយ៍អីជាមួយគ្នាដែរទេ
ជាមួយឪពុកម្តាយ ហាសតា?

ខ៖ មានអនុស្សាវរីយ៍អី

ក៖ ដូចថាធ្លាប់ទៅធ្វើអីគេខ្លះជាមួយគ្នាដែរចឹងហាសតា?

ខ៖ ធ្វើតែស្រែនឹងតែម្តងនឹង

ក៖ ចឹងធ្វើតែស្រែទេណាតា?

ខ៖ នឹងហើយចឹង

ក៖ ចុះឪពុករបស់តាគាត់មានធ្លាប់ប្រាប់ប្រវត្តិទៅតាទេ?

ខ៖ គាត់ឪពុករបស់ខ្ញុំនឹងហោស?

ខ៖ បាទតាឪពុកតា?

ខ៖ គាត់ពីដើមមកឪពុករបស់គាត់នឹងជាមេឃុំ គេហៅមេស្រុកៗហាស

ក៖ បាទតាបាទ?

ខ៖ នឹងហើយ

ក៖ ចុះម្តាយវិញតា?

ខ៖ ម្តាយនឹងធ្វើទាសករ ម្តាយអុំឈឿននឹងហោស?

ក៖ បាទ ចុះគាត់?

ខ៖ ឪរបស់គាត់នឹង

ក៖ គាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងទេតា?

ខ៖ អត់ទេខ្ញុំកើតមកខ្ញុំទាន់ដឹងតែគាត់ពីដើមមកនឹងគាត់ជាមេឃុំជីតារបស់ខ្ញុំនឹងហាស

ក៖ ចុះរួមតៅយាយតាខាងម្តាយវិញតាស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ខាងម្តាយហោស?

ក៖ បាទតានឹងហើយ?

ខ៖ ខាងម្តាយនឹងឪពុករបស់កាត់នឹងឈ្មោះគង់

កៈ ចុះម្តាយវិញតា?

ខៈ ម្តាយនឹងឈ្មោះសៀង

កៈ ចុះយាយតាខាងឪពុកវិញតា?

ខៈ អូ៎!យាយតាខាងឪពុកនឹងខ្ញុំអត់ស្គាល់ទេនឹង

កៈ អូ៎!បាទចុះគាត់កើតនៅណាដែរតាមានដឹងទេ?

ខៈ អ៊ុំឈឿននឹងហោស?

កៈ បាទតាមានដឹងថាគាត់កើតនៅណាដែរទេ?

ខៈ អ៊ុំឈឿននឹងគាត់កើតនៅនឹងនៅឃុំនឹង

កៈ អូ៎!បាទតា ចុះតាមករស់នៅខេត្តនឹងយូរនៅមករស់នៅនឹងយូរនៅ?

ខៈ
អូ៎!យូរហើយតាំងពីគាត់កើតមកខ្ញុំកើតមកក្រោយគាត់ទេគាត់កើតមកនៅនឹងហើយខ្ញុំកើតក្រោយ គាត់ទៀតហើយនឹង

កៈ អូ៎!បាទ
ចុះតាដូចជាមានបងប្អូនរឺមួយក៏កូនចៅណាមួយដែរទៅរស់នៅក្រៅប្រទេសទេតា?

ខៈ ឥឡូវនឹងនេះហាស?

កៈ បាទតាឥឡូវនឹង

ខៈ ឥឡូវនឹងមានមួយដែរគ្រាន់តែជីដូនមួយចឹងទៅណាស់
ជីដូនមួយដែរគាត់នៅអាមេរិចហោស

កៈ គាត់ធ្វើអីគេដែរនៅឯាមេរិចនឹងតា?

ខៈ គាត់នៅខាងនឹងឥឡូវនឹងគាត់មិនដឹងខាងស្អីទេ

កៈ ចុះភរិយារបស់តានឹងគាត់ឈ្មោះអីគេដែរតា?

ខៈ ភរិយាខ្ញុំហោសឈ្មោះគិន ប៉ុន្តែគេស្លាប់បាត់ហើយនឹង

កៈ  អូ៎!ចុះតាមានចងចាំថ្ងៃដែរតាបានរៀបអាពាហ៍ពិពាហ៍ដែរទេតា?

ខៈ  ខ្ញុំរៀបអាពាហ៍ពិពាហ៍ខ្លួនខ្ញុំនឹងហោស?

កៈ  បាទតានឹងហើយ

ខៈ  នៅក្នុងឆ្នាំ1970

កៈ  នៅឆ្នាំ1970ណាតា?

ខៈ  នឹងហើយនៅឆ្នាំ1970នឹង

កៈ
ចុះពេលណុងដូចជាតាជាអ្នករៀបអាពាហ៍ពិពាហ៍ដោយខ្លួនឯងរឺមួយក៏ឪពុកម្ដាយរបស់តាជាអ្នក រៀបអោយដែរតា?

ខៈ  ឪពុកម្ដាយគាត់ជាអ្នករៀបអោយនឹង ឪពុកម្ដាយជាអ្នករៀបអោយនឹង

កៈ  ចុះមានជាជំនូនទេជូនទៅយាយ?

ខៈ  ថាម៉េច?

កៈ  ពេលដែរតាការនឹងមានជាថ្លៃទឹកដោះជូនទៅយាយដែរទេ?

ខៈ  ថីមិនមាន

កៈ  ប៉ុន្តែដូចជាស្អីគេដែរតាពេលណុងហាស?

ខៈ  មានយកថ្លៃផ្ទះយើងទៅដូចថាយកថ្លៃផ្ទះពីខ្ញុំចឹងទៅណាស់

កៈ  បាទតាបាទ?

ខៈ  អោយថ្លៃផ្ទះទៅគាត់ទៅការណុងមានផ្លែឈើអីចឹងទៅ

កៈ  បាទតា ចុះតាចេះអានរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរតា?

ខៈ  អូ៎!ឥឡូវនឹងខ្ញុំសរសេរអក្សរលែងចង់កើតហើយនឹងខ្ញុំភ្លេចអស់ហើយនឹង

កៈ  តារៀនបានថ្នាក់ទីប៉ុន្មានដែរតា?

ខ៖  ខ្ញុំរៀនបានថ្នាក់ទី7នឹងពីដើម

ក៖  អូ៎!ចុះកាលពីរៀននឹងរៀននៅសាលាណាដែរតា?

ខ៖  ខ្ញុំរៀននៅសាលាសំរោងទងហោស

ក៖  អូ៎!បាទតា ចុះតាមានមិត្តភក្តិដែរស្និទ្ធិស្នាលហើយធំធាត់មកជាមួយគ្នាដែរទេតា?

ខ៖  ឥឡូវនឹងហោស?

ក៖  បាទតាបាទ?

ខ៖  កាលពីជំនាន់ណុងចឹមិនមាន

ក៖  ពួកគាត់មានឈ្មោះអីគេខ្លះដែរទៅតា?

ខ៖  អូ៎!ខ្ញុំភ្លេចឈ្មោះគេអស់ហើយនឹងណាស់

ក៖  ប៉ុន្តែធ្លាប់មានប្រវត្តិកាលពីនៅក្មេងៗៗនឹងធ្លាប់បានធ្វើអីជាមួយគ្នាដែរទេតា?

ខ៖  ឈ្មោះហោស?

ក៖  អត់ទេដូចថាធ្លាប់មានអនុស្សាវរីយ៍ជាមួយមិត្តភក្តិជិតស្និទ្ធិរបស់តាហាស?

ខ៖  អូ៎!មានច្រើនណាស់ប៉ុន្តែឥឡូវនឹងវាស្លាប់អស់ហើយនឹងនៅរស់ខ្លះដែរ

ក៖  ប៉ុន្តែតាគិតថាមានអនុស្សាវរីយ៍អីគេខ្លះដែរជាមួយគ្នានឹង
ធ្លាប់តៅស្រែជាមួយគ្នារឺក៏ធ្លាប់ធ្វើអីជាមួយ គ្នាដែរចឹង?

ខ៖
នឹងហោសកាលរៀនសូត្រជាមួយគ្នានឹងគេដល់ពេលដែរឈប់រៀនទៅនឹងខ្ញុំបានឈប់រៀន
នឹងនៅឆ្នាំ 1960នឹងអូ៎ដូចជាឆ្នាំ1958-1959ទេនឹង

ក៖
ចុះតាគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះនឹងតាធ្លាប់បានធ្វើការងារអីគេខ្លះដែរតា?

ខ៖  អត់មានធ្វើអីទេខ្ញុំធ្វើតែឡើងត្នោតនឹង

ក៖  ចឹងតាឡើងត្នោត?

ខ៖
តែមកដល់សម័យឪឡូវនេះនៅសម័យឆ្នាំ1979នឹងមកបានខ្ញុំចេះធ្វើផ្ទះអីចឹងទៅណាស់

ក៖ អ៎ូ!បាទតាបាទ?

ខ៖ ចេះធ្វើគ្រែ ធ្វើតុ ធ្វើទូអីចឹងទៅណាស់

ក៖ ចឹងមានន័យថាតាចេះធ្វើផ្ទះ?

ខ៖ នឹងហើយចេះធ្វើ

ក៖
អ៎ូ!បាទតាគិតថាជីវិតរបស់តាមានការផ្លាស់ប្តូរអីគេខ្លះដែរតាតាំងពីក្មេងរហូតមកដល់ពេលនេះ ហាសតា?

ខ៖
ហេផ្លាស់ប្តូរដែរនឹងហាសពីដើមនឹងខ្ញុំនៅមានកំលាំងខ្ញុំរែកទឹកម្តងនឹងរែកមួយខ្ទះហោស

ក៖ បាទតាបាទ?

ខ៖ ឥឡូវនឹងរែកតែធុងមួយខាងរែកមិនសឹងទាំងរូចផង

ក៖ បាទចុះតាគិតថាម្ហូបអីដែរតាចូលចិត្តពិសារដែរ?

ខ៖
និយាយពីម្ហូបវិញខ្ញុំអត់រើសទេនឹងនិយាយទៅស្រុកស្រែពីដើមនឹងមួយចប់តាំងពីខ្ញុំកើតមកមិន ទាន់មានប៊ីចេងហូបហោស នៅម្ហូបឆ្ងាញ់ទាំងអស់នឹងពីដើមធម្មជាតិហាស

ក៖ បាទតាចុះ?

ខ៖ ត្រីសាច់អីនឹងធម្មជាតិ
សាច់ជ្រូកអីនឹងសុទ្ធតែធម្មជាតិហាសយើងមិនប្រើថ្នាំដូចឥឡូវនឹងទេណាស់

ក៖ ចុះតាគិតថាល្បែងប្រជាប្រិយ៍អីដែរតាគិតថាចូលចិត្តលេងតាំងពីក្មេងហាសតា?

ខ៖ ពីដើមមកនឹងខ្ញុំអត់មានប្រជាប្រិយ៍អីទេមានតែល្បែងរាំវង្ស នឹងរាំក្បាច់នឹងអីទេ

ក៖ បាទតាំចូលចិត្តរាំហោសតា?

ខ៖  តែក្បាច់ឥឡូវនឹងមិនមែនបទឆ្លុតចេះទេនឹង បទឥឡូវនឹងបទខ្ញុំលែងចូលចិត្តហើយនឹង

ក៖  ប៉ុន្តែតាចូលចិត្តវាំណតា?

ខ៖  អូ៎!ខ្ញុំចូលចិត្តណាស់ពីដើមនឹង ពីដើមទៅធ្វើបុណ្យធ្វើទាន់អីនឹងម្តាយឪពុកអោយ4-10រៀលអីនឹងអត់ បានមាននុំស៊ីទេ

ក៖  ទៅតែវាំនឹងតែម្តង?

ខ៖  ទៅទិញតែសំបុត្រវាំនឹង

ក៖  អូ៎!ហ្វចឹងហោសតា?

ខ៖  មានសំបុត្រ2រៀល ទៅ3រៀលអីចឹងទៅណាស់

ក៖  បាទចុះតាចេះច្រៀងអត់តា?

ខ៖  អូ៎!ពីដើមនឹងចេះដែរប៉ុន្តែឥឡូវនឹងខ្ញុំលែងចេះហើយនឹង

ក៖  ចុះតាចូលចិត្តស្តាប់បទចំរៀងអត់តា?

ខ៖  ខ្ញុំចូលចិត្តណាស់ពីដើមនឹងលក្ខណះមិនមែនចំរៀងឥឡូវនឹងទេណាស់

ក៖  បាទតាបាទ?

ខ៖  ចំរៀងស៊ិនស៊ីសាម៉ុតហោស

ក៖  ចុះមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសាររបស់តានឹងចេះលេងឧបករណ៍ភ្លេងដែរទេ?

ខ៖  ឥឡូវនឹងហោសអត់មានទេ

ក៖  បាទតា ផ្ទះរបស់តានឹងលក្ខណះបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖  ហឺផ្ទះរបស់ខ្ញុំនឹងពីដើមផ្ទះធម្មតាដូចតែគេដុចឯងដែរនឹងប៉ុន្តែឥឡូវនឹងខ្ញុំអត់តែម្តងនឹង

ក៖  អូ៎!ចឹងហោសតា?

ខ៖  ខ្ញុំនៅអន់ជាងគេបំផុតនៅក្នុងភូមិនេះផ្ទះតៀមនៅនឹងដីនឹង

កៈ ប៉ុន្តែគិតថាផ្ទះមួយនឹងនរណាគេជាង្អកសាងសងដែរតា?

ខៈ ខ្ញុំនឹងណាស់

កៈ អូ៎!តាធ្វើដោយខ្លួនឯងណាតា?

ខៈ នឹងហើយ

កៈ អូ៎!ចឹងតាចេះធ្វើផ្ទះ?

ខៈ ខ្ញុំចេះធ្វើផ្ទះនឹង

កៈ ចុះនរណាគេបានបង្រៀនអោយតាចេះធ្វើដែរ?

ខៈ
ហីកាលពីនៅជំនាន់ពលពតនឹងគេអោយខ្ញុំដើរធ្វើផ្ទះអីនឹងហាសកាលនៅរបបនោះនឹងដើរធ្វើតែផ្ទះ នឹងណាស់

កៈ អូ៎!បាទចុះតាគិតថាជំនាញអីដែរតាគិតថាចេះស្ទាត់ជំនាញដែរតា?

ខៈ ជំនាញនឹងធ្វើផ្ទះនឹងហើយនឹងធ្វើ តុ ធ្វើទូអីនឹង

កៈ អូ៎!បាទតាចុះ?

ខៈ ខ្ញុំចេះធ្វើប៉ុណ្ណឹងមនុស្សប្រុសនឹង ពីដើមមកឡើងតែដើមត្នោតទេពីដើមនឹង

កៈ
ចុះតាអាចប្រាប់ពីពេលដែរនៅជំនាន់កាលពីតានៅតូចហើយរហូតដល់ពលពតនឹងអ៊ីសារ៉ាក់ នឹងលុនណុល?

ខៈ ជំនាន់អ៊ីសារ៉ាក់នឹងខ្ញុំរត់តែចូលទៅក្នុងព្រៃជាមួយម៉ែជាមួយឪខ្ញុំនឹង

កៈ ចុះនៅជំនាន់លុនណុលវិញតា?

ខៈ ជំនាន់លុនណុលនឹងខ្ញុំធ្លាប់ធ្វើជាទាហ៊ានដែរនឹង

កៈ តានៅធ្វើជាទាហ៊ានហោសតា?

ខៈ នឹងហើយ

កៈ ប៉ុន្តែមានការលំបាកអីទេដែរតា?

ខៈ អត់អីទេខ្ញុំអើរលំបាកដែរកាលណាមានបាញ់គ្នាអីចឹងទៅលំបាកដែរនឹង ធ្លាប់បាញ់គ្នាធ្លាប់អីនឹង ដល់ក្រោយមកខ្ញុំធ្វើដល់វីខនអីនឹងដល់គុកអីនឹង

កៈ ចុះតាគិតថាកាលពីជំនាន់ពលពតនឹងតាមានការលំបាកអីគេដែរទៅតា?

ខៈ ខ្ញុំជំនាន់ពលពតនឹងលំបាកដែរនឹងលំបាកត្រង់យើងហូបមិនឆ្អែតទេ

កៈ ប៉ុន្តែពេលណុងតាឈប់ធ្វើជាទាហ៊ានហើយណតា?

ខៈ ខ្ញុំឈប់ហើយប៉ុន្តែខ្ញុំប្រាប់គេថាខ្ញុំអត់ធ្វើជាទាហ៊ាន

កៈ អូ៎!បាទតាចឹង?

ខៈ ម្ល៉ោះហើយគេមិនយកខ្ញុំទៅសំលាប់ចោលទេនឹង

កៈ ប៉ុន្តែពេលណុងគេជំលាសតាទៅណាដែរទៅចឹង?

ខៈ អត់ទេនៅស្រុកណុងចេញពីនឹងទៅនៅខាងភូមិឆ្ងាយហោស

កៈ នៅភូមិអីគេដែរតា?

ខៈ ភូមិភ្នាយ

កៈ នៅភូមិភ្នាយ អូចុះ?

ខៈ

ហើយដល់ពេលចឹងគេតាមដានមានគេរាយការណ៍ថាខ្ញុំធ្វើជាទាហ៊ាននៅជំនាន់ពលពត ហាស

កៈ បាទចឹងតា?

ខៈ

នៅជំនាន់លុនណុលហាសម្ល៉ោះហើយគេតាមសំលាប់ខ្ញុំហោសប៉ុន្តែខ្ញុំដោះស្រាយចេញរួច បានទាំង អស់នឹងណាស់
គេហៅខ្ញុំមកសួរហើយគេអង្គការនឹងគេហៅខ្ញុំចេញទៅធ្វើនៅកន្លែងស្រុកអីចឹងទៅ ណាស់

កៈ បាទតានឹង?

ខៈ
ហេដក់គេអ្នកភូមិនឹងគេដឹងថាខ្ញុំធ្វើជាទាហ៊ាននឹងគេសុំខ្ញុំមកនៅភូមិវិញខាងស្រុកនឹងគេថាមិនអោយ ទៅទេនឹងអោយគាត់ទៅនរណាគេធ្វើផ្ទះ

កៈ អូ៎!ពេទ្យណុងតាជាអ្នកធ្វើផ្ទះអោយគេហើយៗណាតា?

ខៈ ចឹងទៅខ្ញុំក៏នៅរស់ទៅនឹង

កៈ អូ៎!បាទប៉ុន្តែបងប្អូនរបស់តាទៅណាដែរទៅចឹង?

ខៈ នៅតែផ្ទះនឹង

កៈ នៅតែផ្ទះដែរពេលណុង?

ខៈ នឹងហើយចឹង

កៈ ចឹងមានន័យថាតារស់នៅបែកពីគ្រួសារមែនទេតា កាលពីជំនាន់ណុង?

ខៈ អត់បែកទេ

កៈ អូ៎!គេជំលាសទៅទាំងអស់គ្នាតែម្តងនឹងគ្រួសាររបស់តា?

ខៈ នឹងហើយទៅទាំងអស់គ្នានឹង

កៈ អូ៎!តាពេលណុងមានគ្រួសារហើយនៅតា?

ខៈ ខ្ញុំមានគ្រួសារហើយនឹងខ្ញុំមានតាំងពីឆ្នាំ1970នឹងមក

កៈ មានគ្រួសារហើយនឹងមានកូនអីទៀតណាតា?

ខៈ នៅទេមិនទាន់មានកូនទេទាល់តែឆ្នាំ1976នឹងបានមានកូនមួយនេះ

កៈ អូ៎!បាទតា
ចុះតាគិតថារហូតដាច់ពលពតនឹងមកតាធ្លាប់មានជួបការលំបាកអីផ្សេងដែរទេតា?

ខៈ យើងលំបាកដែរនឹង

កៈ ចុះកាលណុងគេមិនទាន់ចាយលុយទេចឹងគេប្រើអីគេដែរទៅតា?

ខ៖ កាលពីយើងមិនទាន់ចាយលុយនឹងយើងប្រើអង្ករអីនឹងហាស ចុះយើងមិនទាន់រកអីបានទេកាលពី ជំនាន់ពីដើមនឹង

ក៖ ប៉ុន្តែយើងយកអង្ករគេមកហូប?

ខ៖ ដូរយកអង្ករចឹងទៅ

ក៖ ភាគច្រើនគេឡើងត្នោតនឹងគេឡើងយកអីគេដែរតា?

ខ៖ ពីដើមហោស?

ក៖ គេឡើងត្នោតនឹងគេឡើងយកអីគេដែរ?

ខ៖ គេឡើងយកស្ករនឹងយកមកលក់ហោស

ក៖ ឡើងយកស្ករធ្វើទុកលក់នឹងមែនតា?

ខ៖ នឹងហើយ

ក៖ អូ៎!ភាគច្រើនយើងរកបានច្រើនដែរណាតា?

ខ៖ អូ៎!ខ្ញុំឡើងមួយថ្ងៃនឹងបានមួយពាងកន្លះហោស

ក៖ អូ៎!បានច្រើនដែរនឹងហោសតា?

ខ៖ នឹងហើយបើគិតជាឥឡូវនឹងវិញហោសថ្លៃណាស់

ក៖ ប៉ុន្តែឥឡូវនឹងតាឡើងលែងរួចហើយណាតា?

ខ៖ ខ្ញុំឡើងលែងកើតហើយនឹង

ក៖ ដោយសារតែតាចាស់ហើយណាតា?

ខ៖ នឹងហើយចាស់ហើយ

ក៖ ចុះតាគិតថាតាឆ្លងកាត់ឧបសគ្គនឹងការលំបាកនឹងដោយរបៀបណាដែរនឹងពីការលំបាករបស់តា ចឹងហាស?

ខ៖ ការលំបាកដែរនឹងខ្ញុំលំបាកត្រង់ការពីកំលាំងនឹងនៅមានខ្ញុំចេះតែធ្វើកើតហើយណាស់

កៈ បាទតាចឹង?

ខៈ
ដល់ពេលឥឡូវនឹងធ្វើអីកើតគេរកដែរគេរកធ្វើនេះធ្វើនោះប៉ុន្តែខ្ញុំធ្វើលែងកើតហើយឥឡូវនឹងភ្នែកក៏ងងឹតពីដើមភ្នែកភ្លឺនឹងខ្ញុំធ្វើបានទាំងអស់នឹង

កៈ អូ៎!បាទតាចឹង?

ខៈ ស្រែក៏ខ្ញុំចេះធ្វើភ្ជួរ ឡើងត្នោតនឹងក៏ខ្ញុំចេះឡើងដែរធ្វើផ្ទះក៏ខ្ញុំចេះធ្វើ

កៈ ចឹងមានន័យថាតាចេះច្រើនមុខហាសណាតា?

ខៈ នឹងហើយ

កៈ ចុះតារៀនមួយនឹងមកពីនរណាគេដែរតា?

ខៈ បាទថាម៉េច?

កៈ តាចេះដោយខ្លួនឯងរឺក៏តារៀនមកពីនរណាគេដែរ?

ខៈ
កាលពីជំនាន់ពលពតនឹងអើរគេមានមេជាងគេចាស់ៗៗនឹងយើងទៅធ្វើជាមួយគាត់ដែរចឹងទៅណាស់

កៈ បាទតាចឹង?

ខៈ ដល់ពេលដែរធ្វើយូរៗៗទៅយើងចេះហើយនឹង

កៈ អូ៎!យើងទៅរៀនជាមួយគេទៅមើលគេធ្វើ?

ខៈ ធ្វើគុ ធ្វើទូ ធ្វើគ្រែអីនឹងចាំបាច់អីទៅមើលតែគេធ្វើទៅ
ទូគ្រែដែរគេយកមកលក់នឹងដល់ពេលចឹងទៅ បានមើលហើយអាចធ្វើបានហើយនឹង

កៈ បាទតា
ចុះតាគិតថាពេលណាដែរតាគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់តាដែរ?

ខៈ ឥឡូវនឹងគ្មានពេលណាសប្បាយទេនឹង

កៈ ប៉ុន្តែពីមុនហាសតាកាលពីពេលដែរតានៅក្មេងរឺក៏អីចឹង?

ខៈ កាលពីខ្ញុំនៅក្មេងនឹងខ្ញុំសប្បាយហាសទោះឡើងត្នោតមែន

កៈ ចឹងហោសតា?

ខៈ សុំម៉ែទៅបុណ្យអីនឹងម៉ែអោយ10-20រៀលអីនឹងយកទៅរាំអីទៅ

កៈ ចុះតាកាលពីនៅក្មេងហាស
តាធ្លាប់មានគោលបំណងតាពេលដែរធំឡើងនឹងតាចង់ធ្វើអីទេតា?

ខៈ កាលពីខ្ញុំនៅរៀននឹងខ្ញុំនឹកឃើញពីក្មេងនឹងដល់ពេលដែរខ្ញុំធំមកនឹងមិនដែរអីទេ
ពួកខ្ញុំរៀនតាំងពី ថ្នាក់ទី12កាលពីដើមហាស

កៈ បាទតាបាទ?

ខៈ រហូតមកដល់ថ្នាក់ទី7នឹងមិនដែរមានលេខ2ទេ

កៈ អូ៎!លេខមួយរហូតនឹងហោសតា?

ខៈ បានលេខមួយរហូតនឹង

កៈ អូ៎!ខ្លាំងហើយតា?

ខៈ មានតែលោកគ្រូអោយលុយចាយទៀតនឹង
តែដល់ពេលដែរប្រលងនៅឆ្នាំ1971នឹងអូនៅឆ្នាំ1960 នឹងហាស

កៈ បាទតាបាទ?

ខៈ ប្រលងនៅឆ្នាំណុងដូចថាគេចង់ជំរុះចោលអោយអស់តែម្តងនឹងមនុស្ស5000នាក់
នឹងគេយកតែមនុស្ស100នាក់ទេ

កៈ ប៉ុន្តែតាប្រលងជាប់ដែរ?

ខៈ អត់ទេ

កៈ តាប្រលងធ្លាក់ដែរ?

ខៈ ប្រលងធ្លាក់ទាំងអស់នឹង ដល់ពេលដែរធ្លាក់អស់នឹងខ្ញុំក៏ឈប់តែម្តងនឹងទៅ

កៈ ពេលណុងតាខឹងពេក?

ខៈ ចុះខឹងពេកចុះបើមនុស្ស5000នាក់ គេយកតែមនុស្ស100នាក់

កៈ សុទ្ធតែអ្នកខ្លាំងៗហើយនឹង?

ខៈ
ខ្លាំងហើយសូម្បីតែគ្រូដែរទៅធ្វើមេប្រយោគប្រលងនឹងក៏ប្រាប់ខ្ញុំដែរណាស់ថាអត់ទេកូនសិស្សនឹង ក៏អត់មានជាប់ដែរធ្លាក់ទាំងអស់នឹង
ចុះបើចំនោទដែរយកមកដាក់អោយធ្វើនឹងហាសថ្នាក់ទី3នឹងយក
មកអោយថ្នាក់ទី7ធ្វើនឹងមនុស្សដែរថ្នាក់ទី7នឹងដែរទាន់រៀនហោស
ចឹងមានធ្វើអីត្រូវទៅអត់ត្រូវទាំងអស់
នឹងម៉ា5000នាក់នឹងយក100នាក់នឹងហាសមួយខេត្តកំពង់ស្ពឺនឹងហាស

កៈ ចឹងធ្លាក់ទាំងអស់នឹងហោសតា?

ខៈ បានធ្លាក់ទាំងអស់នឹង

កៈ អូ៎!ចឹងចុះ?

ខៈ ដូចថាគេជំរុះហាស

កៈ
បាទតាគេចង់ជំរុះយកអ្នកខ្លាំងៗតែម្តងនឹងចង់ដឹងថាបើយើងមិនបានរៀនចឹងទៅយកបាន ប្រលងជាប់អត់នឹង?

ខៈ
អើរបានជាប់ដែរបានជាប់100នាក់នឹងគេសរសេរចំនោទនឹងមិនត្រូវប៉ុន្តែគេបានខាងផ្សេងអីចឹង ទៅណាស់

កៈ បាទតា
ចុះបើសិនជាចង់អោយតាផ្តែផ្តាំអោយទៅកូនចៅជំនាន់ក្រោយៗនឹងតើតាចង់ផ្តែផ្តាំអីទៅពួកគាត់ដែរតា?

ខ៖
ផ្ដែផ្ដាំតែកូនចៅនឹងថាធ្វើម៉េចអោយតែចេះគិតរឿងរកស៊ីសព្វថ្ងៃនឹងកុំធ្វើហួសហេតុចាយវាយខុស ក្បួនសុខខ្នាត កុំអោយប្រព្រឹត្តនៅអំពើដៃរខុសហាស

ក៖ ចុះបើតាចង់ហាមឃាតអត់ចង់អោយគាត់ធ្វើអីជៀងរៀងវិញហាស តើតាចង់អោយពួកគាត់ ជៀសរៀងអីគេដែរទៅតា?

ខ៖ ជៀសរៀងសម័យឥឡូវនឹងវាមានថ្នាំជក់ថ្នាំអីចឹងទៅណាស់

ក៖ បាទចឹងតាអត់ចង់អោយពួកគាត់ជៀសរៀងណាតា?

ខ៖ កុំអោយប៉ះពាល់អានឹង

ក៖ បាទចឹងមានអីចង់ផ្ដែផ្ដាំទៀតទេតា?

ខ៖
ហេមានផ្ដែផ្ដាំអីមានតែផ្ដែផ្ដាំកូនចៅនឹងតែប៉ុណ្ណឹងថាកូនចៅបើកូនឯងកុំអោយមានបញ្ហាមួយនឹង កុំអោយមានប៉ះពាល់អាគ្រឿងញៀននឹងអោយសោះនឹង

ក៖ ដោយសារតែមួយនឹងធ្វើអោយប៉ះពាល់ដល់ជីវិតរបស់មនុស្សណាតា?

ខ៖ នឹងហើយប៉ះពាល់ដល់ជីវិតរបស់មនុស្ស ខ្ញុំឆ្ងល់ចេះវិញឆ្ងល់ត្រង់ថាគ្រឿងញៀននឹងគេរកជាតិស្អីរឺក៏រកថ្នាំអីអាចធ្វើអោយកូនសំលាប់ម៉ែឪបាននឹង

ក៖ ខ្ញុំអត់ដឹងដែរតា?

ខ៖ ខ្ញុំឆ្ងល់តែត្រង់នឹងហាសពីដើមនឹងបើថាមានចេះបាឡីអីចឹងទៅមិនថាទេ
ហើយអាគ្រឿងញៀននឹង
យកមកអាកូនៗនឹងជក់គ្រឿងញៀននឹងអីយូរៗទៅលួចរបស់ម៉ែលួចរបស់ឪ
ហើយនឹងហ៊ានសំលាប់ ឪទៀតនឹង

ក៖ បាទតានឹងហើយ?

ខ៖ មានគេផ្សាយរាល់ដងដែរតើនឹង

ក៖ លឺតាលឺៗនឹងតា?

ខ៖ នឹងហើយគេផ្សាយ

ក៖ អូ៎!ចឹងតាអត់មានអីចង់ផ្ដែផ្ដាំទៀតទេណាតា?

ខ៖ ចឹងខ្ញុំមិនដឹងថាផ្ដែផ្ដាំអីទៀតទេ

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនតាដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់តា
ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលា
ដើម្បីតំកល់ទុកអោយតានៅពេលក្រោយចឹងបាសតា?

ខ៖ បាទនឹងហោស?

ក៖ បាទចឹងអរគុណច្រើនតា៕៕៕